# សិលាចារឹកប្រាសាទភ្នំត្រុប់ K.94

ប្រាសាទភ្នំត្រុប់ មានទីតាំងស្ថិតស្រុកបាធាយ ខេត្តកំពង់ចាម ហើយសិលាចារឹកដែលលើកយកមកសិក្សានេះ ដំបូងឡើយស្ថិតនៅទីតាំងប្រាសាទផ្ទាល់ តែក្រោយមកគេបានយកមករក្សាទុកនៅសារមន្ទីរជាតិនាទីក្រុងភ្នំពេញយូរណាស់មកហើយ ដោយចុះលេខសម្គាល់ D75។ ក្រោយមកទៀត គេបានដឹកជញ្ជូនយកទៅរក្សាទុកនៅមន្ទីរអភិរក្សដ្ឋានអង្គរ រហូតមកដល់បច្ចុប្បន្ន។ អត្ថបទនេះ ធ្លាប់មានអ្នកស្រាវជ្រាវបរទេសល្បីៗសិក្សាជាច្រើនលើកមកហើយ។ ប៉ុន្តែ នៅក្នុងអត្ថបទនេះ ខ្ញុំនឹងពិនិត្យម្តងទៀតលើការសិក្សារបស់អ្នកស្រាវជ្រាវបរទេស។ តើសិលាចារឹកប្រាសាទភ្នំត្រុប់មានលក្ខណៈ ខ្លឹមសារ និងអត្ថន័យបែបណាខ្លះ?

នៅដើមសតវត្សរ៍ទី២០ លោក អេដែន អែម៉ូញ៉េ មិនបានបកប្រែសិលាចារឹកនេះទាំងស្រុងនោះទេ តែលោកបានធ្វើសេចក្តីសង្ខេបខ្លឹមសាររួមរបស់សិលាចារឹកនេះ ព្រមទាំងបានយោងលើការវិភាគរបស់លោក អាបែលបាហ្គេញ ផងដែរ។ លោកអែម៉ូញេ បានបន្ថែមទៀតថា នេះជាការប្រតិស្ឋានព្រះស្រីកទ្រោទយេស្វរ។ គាត់សន្មត់ថា ទេពដែលរៀបរាប់នៅក្នុងសិលាចារឹកនេះ គឺទំនងជាទេពនៅក្នុងរជ្ជកាលរបស់ព្រះបាទឧទយាទិត្យវម៌្ម ដែលទ្រង់គ្រងរាជ្យតាំងពីមហាសករាជឆ្នាំ ៨៧១ មកម្ល៉េះ។ បន្ទាប់មកលោក លុយណេ ដឺឡាហ្សុងគៀ្យ បានយកព័ត៌មាននេះមកផ្សព្វផ្សាយម្តងទៀត ដោយលោកយោងទៅតាមការបកស្រាយរបស់លោក អែម៉ូញេ និងលោក អាបែលបាហ្គេញ។

លោក អាបែលបាហ្គេញ បានបានធ្វើសេចក្តីសង្ខេប និងអំណានអត្ថបទឱ្យបានត្រឹមត្រូវនូវកាលបរិច្ឆេទទាំង៣គឺ ៨៧៥, ៨៨២ និង៨៨៤ នៃមហាសករាជ (ត្រូវនឹងគ.ស. ៩៥៣, ៩៦០, ៩៦២) ប៉ុន្តែកំហុសរបស់គាត់នៅត្រង់ថា គាត់បានយកម្ចាស់មូលនិធិ គឺព្រះស្រីកក្តិវិក្រម ថាជាព្រះឬទេពទៅវិញ។ ចំណែកឯ ព្រះកទ្រោទយេស្វរ ដែលបានប្រតិស្ឋានឡើងនៅក្នុងឆ្នាំមហាសករាជ ៨៧៥ (គ.ស.៩៥៣) លោកយល់ថា ជាម្ចាស់មូលនិធិទៅវិញ។

បើយោងទៅតាមលោក ហ្សក សឺដេស បានលើកឡើងថា សិលាចារឹកនេះចារឹកនៅលើមេទ្វារខាងជើងច្រកចូលប្រាង្គកណ្តាល។ នៅក្នុងសិលាចារឹកនេះគ្មានព័ត៌មានអំពីព្រះមហាក្សត្រនោះទេ លោក សឺដេស បានយោងទៅលើកាលប្បវត្តិរបស់សិលាចារឹកនេះ គាត់បានសន្និដ្ឋានថា ព្រឹត្តិការណ៍នៅក្នុងសិលាចារឹកស្ថិតក្នុងរជ្ជកាលរបស់ព្រះបាទរាជេន្ទ្រវម៌្ម (គ.ស.៩៤៤ ដល់ ៩៦៧)។ សិលាចារឹកនេះចារឹកជាភាសាសំស្រ្កឹត មានចារឹកអក្សរចំនួន ១២ បន្ទាត់ ឬបើគិតជាស្លោកមានចំនួន ៣ ស្លោក និពន្ធបែបកំណាព្យវសន្តតិលកាឆន្ទ។ ការសិក្សារបស់លោក បានបោះពុម្ពផ្សាយ

អត្ថបទដោយៈ កំ វណ្ណាក់

ជាភាសាបាលី ប៉ុន្តែ ជនជាតិខ្មែរមួយចំនួនធំ មិនមានសមត្ថភាពអាចអាន និងយល់ភាសាបាលីបានឡើយ។

តាមការសិក្សាឡើងវិញនៅពេលនេះ យើងពិនិត្យឃើញថា នៅក្នុងអំណានរបស់លោក សឺដេស បានកាត់សន្ធិនូវបទមួយចំនួនដើម្បីងាយស្រួលដល់ការអានតាមលំនាំបែបរបស់អឺរ៉ុប។ ការផ្ដាច់សន្ធិបែបនេះ នាំឱ្យមានគុណសម្បត្តិដល់អ្នករៀនសំស្រ្កឹតដំបូង ពោល គឺងាយស្រួលដល់ការអាន ប៉ុន្តែក៏មានផលលំបាកមួយចំនួនដល់អ្នករៀនសំស្រ្កឹតដំបូងដូចគ្នា ពោល គឺក្នុងសិលាចារឹកសរសេរផ្សេង លោក សឺដេស សរសេរផ្សេង នាំឱ្យខុសទៅនឹងគណៈឆន្ទតាមក្បួនកាព្យសាស្ត្រ និងធ្វើឱ្យបាត់សម្ងួស្សរខាងសព្ទាលង្ការថែមទៀតផង។ ឧទាហរណ៍ ៖ នៅក្នុងសិលាចារឹសរសេរថា៖

- **តនុភិរ៌្វិកុតា** ទៅជា **តនុភិរ៑ វិកុតា**
- **ស្ថិតគ្ត្រី** ទៅជា **ស្ថិតគ៑ ត្រី**
- **ឥហាជមតិម្ទិបត្យះ** ទៅជា **ឥហាជមិ អតិម្ទិបតិ សះ**
- **វិក្រមុបេន្ទ្រមតិម្ទិបត្យះ** ទៅជា **វិក្រមិ ឧបេន្ទ្រមិ អតិម្ទិបតិ សះ។**

ចំពោះខ្លឹមសារទាំងស្រុងរបស់សិលាចារឹកនេះ គឺការប្រតិស្ឋានព្រះបដិមា **ព្រះស្រីភទ្រេទយេស្វរ** នៅក្នុងឆ្នាំមហាសករាជ ៨៧៥ (ត្រូវនឹងគ.ស.៩៥៣) និង **ស្រីភក្តិវិក្រម** បានប្រតិស្ឋានព្រះ**អជ** នៅក្នុងឆ្នាំមហាសករាជ ៨៨២ (ត្រូវនឹងគ.ស.៩៦០) បន្ទាប់មក គឺការប្រតិស្ឋានព្រះបដិមា**ព្រះឧបេន្ទ្រ** ក្នុងឆ្នាំមហាសករាជ ៨៨៤ (ត្រូវនឹងគ.ស.៩៦២)។

### អត្ថបទពាក្យចារឹក

## វសន្តតិលកាឆន្ទ

១. កីដាន្តមីនធនុវ្ឫឝ្ចិកមាគ៌្គមាគ៌្គេ កីដាទិបាគ៌្វនយនោទ្កវ អាទិទេវះ
បីថេថ៌គៃលតនុភិរ៌្វិកុតាស្ថិតគ្ត្រី ភទ្រេទយេឝ្វរ ឥតិ ប្រថិតាភិធានះ។

២. ទ្វន្ទាក៌សោម្យក្ឫគុកោមតុលាទ្វ៌ចន្ទ្រ សិង្ហោទ្កវាមរគុរៅ មករាក៌សូនៅ
នេត្រាប្តម្វត្តិគុចិយាមទិនេបុ គុភេ្វ ឝ្រីភក្តិវិក្រម ឥហាជមតិម្ទិបត្យះ។

៣. វេធ៌ាលិមធ្យមិថុនស្ថនតៅលមីនា ម្កោក្ឫទ្វពេ ក្សណេគតេក៌មុខេ ស លគ្នេ
វេទាប្តមង្គលសមាជវហ្និក្ឫណ្ហេ ឝ្រីភក្តិវិក្រមុបេន្ទ្រមតិម្ទិបត្យះ។

អត្ថបទដោយ៖ កំ វណ្ណារ៉ា

## បំណកប្រែ

១. ខាងចុងទៅគោចរចាប់ពី គឺជ=វ្ឫស្ចិកពាសី មិនរាសី ធនុរាសី វ្ឫស្ចិករាសី មក៌ដរាសី និង កក៌ដរាសី ព្រះអាទិត្យរះឡើង ចាប់ផ្ដើមពីវ្ឫស្ចិករាសី ក្នុងឆ្នាំមហាសករាជកំណត់ដោយ តនុ=៨ គែល ៧ អចំ=៥= មហាសករាជឆ្នាំ ៨៧៥ ជាពេលបានប្រតិស្ថានទេវបដិមា ដែលមានព្រះនាមថា **ស្រីកម្រោទយេស្វរ** ហើយបានតម្កល់នៅលើបល្ល័ង្ក។

២. ផ្កាយព្រះអាទិត្យ សោម្យ=ផ្កាយពុធ ផ្កាយសុក្រ ភោម=ផ្កាយព្រះអង្គារ៍ ស្ថិតជាគូនឹងគ្នា ព្រះចន្ទមួយចំណិតស្ថិតនៅត្រង់ (អទ្ធ៌ចន្ទ្រ) តុលរាសី ផ្កាយព្រហស្បតិ៍ ស្ថិតក្នុងសីហរាសី ផ្កាយព្រះសៅរ ស្ថិតនៅមកររាសី ក្នុងឆ្នាំកំណត់ដោយ មូត្តិ៍=៨ អម្ពុ=៨ នេត្រ=២= មហាសករាជ ៨៨២ ក្នុងថ្ងៃយាម ខែសុចិ ខាងសុក្លបក្ស ពេលនេះ **ព្រះស្រីភក្តិវិក្រម** បានប្រតិស្ថានព្រះបដិមា **ព្រះអជ** នៅត្រង់ទីកន្លែងនេះ។

៣. ស្ថិតនៅក្នុងឧសភរាសី ពាក់កណ្ដាលវិច្ឆិការាសី ផ្កាយក្ងោះ កុម្ភរាសី តុលរាសី មិនារាសី និងកុម្ភរាសី ក្នុងពេលនេះព្រះអាទិត្យស្ថិតនភាបាទ (ជើងមេឃ) នៅក្នុងឆ្នាំកំណត់ដោយ មង្គល=៨ អម្ពុ=៨ វេទ=៤ ថ្ងៃចន្ទ ខែមាឃរ ខាងក្ឫស្ណបក្ស(រនោច) ក្នុងពេលនោះ **ព្រះស្រីភក្តិវិក្រម** បានប្រតិស្ថានព្រះបដិមា **ព្រះឧបេន្ទ្រ (វិស្ណុ)**។

សរុបជារួមមក សិលាចារឹកភ្នំត្រប់ គឺជាសិលាចារឹកភាសាសំស្រ្កឹតមួយផ្ទាំង ដែលបង្ហាញអំពីព័ត៌មានខាងហោរាសាស្រ្ត និងតារាសាស្រ្តជាច្រើន ដែលមនុស្សជំនាន់មុនពិតជាមានជំនាញយ៉ាងច្បាស់លាស់លើប្រព័ន្ធតារាសាស្រ្តមួយនេះ។ ព័ត៌មានជាទូទៅ បានផ្ដល់ឱ្យយើងដឹងអំពីតម្កល់ព្រះនៅក្នុងប្រាសាទក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន។ ម្យ៉ាងវិញទៀត យើងសម្គាល់ឃើញថា បើទោះបីចម្លាក់នៅលើជញ្ជាំងប្រាសាទភ្នំត្រប់បង្ហាញអំពីទេពនៅក្នុងព្រះពុទ្ធសាសនាវជ្រយានក៏ពិតមែន ប៉ុន្តែព័ត៌មានសិលាចារឹកដែលរកឃើញនៅទីនេះបញ្ជាក់បន្ថែមថា នៅទីនេះក៏ប្រណិបតន៍ព្រហ្មញ្ញសាសនាផងដែរ។

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ១៖ ប្រាសាទភ្នំត្រប់ ស្រុកបាធាយ ខេត្តកំពង់ចាម (មើលពីមុខខាងកើត)



រូបលេខ២៖ វត្ថុសិល្បៈមួយចំនួននៅប្រាសាទភ្នំត្រប់

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៣៖ សំណៅផ្តិតសិលាចារឹកប្រាសាទភ្នំត្រប់ (ផ្តិតដោយ៖ កំ វណ្ណារ៉ា និង ហេង ដា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា